# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ដឹកនាំប្រតិភូក្រសួងឧស្សាហកម្ម និង សិប្បកម្ម ចុះសួរសុខទុក្ខ កងទ័ពប្រចាំទិសប្រាសាទព្រះវិហារ

ដើម្បីតភ្ជាប់មនោសញ្ចេតនា រវាងមន្ត្រីរាជការ ជាមួយកងទ័ពសមរភូមិមុខ ថ្ងៃទី១ ខែធ្នូ ឆ្នាំ ២០១៤ គណៈប្រតិភូដឹកនាំដោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម រួមជាមួយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចុះសួរសុខទុក្ខកងទ័ព នៅកងពលតូចអន្តរាគមន៍លេខ៨ ដែលកំពុងឈរជើងការពារទឹកដី នៅតំបន់ប្រាសាទព្រះវិហារ ដោយនាំយកអំណោយជាសំភារៈនិងថវិកាឧបត្ថម្ភមួយចំនួនផងដែរ ។







ក្នុងកិច្ចសំណេះសំណាលនេះដែរ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានលើកឡើងថា ចំណងសម្ព័ន្ធមេត្រីភាពរវាងកងកំលាំង គឺជាចំណងមេត្រីភាពមិនអាចកាត់ផ្តាច់បាន ព្រោះថាពេលដែលប្រទេសជាតិយើងមានទុក្ខ គឺដោយសារកងទ័ពប្តូរស្លាប់រស់ ហើយពេលដែលប្រទេសជាតិយើងបានជោគជ័យ ក៏ដោយសារកងទ័ពដែរ ។






ឯកឧត្តមទេសរដ្ឋមន្ត្រី បានថ្លែងនូវការកោតសរសើរ ចំពោះគំរូវីរៈភាព របស់បងប្អូនកងទ័ព ដែលបានលះបង់ ហ៊ានធ្វើពលីកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុការពារជាតិមាតុភូមិ ជាពិសេស ជូនដល់ភាពសុខសាន្តរបស់ប្រជាជនទូទាំងប្រទេសបានសុខសន្តិភាពផងដែរ ។

មានប្រសាសន៍ស្វាគមន៍គណៈប្រតិភូក្នុងឱកាសនោះ នាយឧត្តមសេនីយ៍ **ជា តារា** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាប្រធានទិសយោធភូមិភាគទី៤ បានលើកឡើង ពីសភាពការណ៍ ព្រំដែន កើតមានឡើងរយៈពេល៧ឆ្នាំមកនេះ ដែលកងទ័ពយើងរឹងមាំប្រកប ដោយឆន្ទៈប្រយុទ្ធប្តូរផ្តាច់ អនុវត្តសិទ្ធស្វ័យការពារទឹកដីដ៏មានប្រសិទ្ធិភាព និងការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិ បណ្ឌិត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឲ្យទាហានសៀមដកចេញអស់ពីទឹកដីកម្ពុជា ក្នុងតំបន់ប្រាសាទព្រះវិហារ ពិសេសទាហ៊ាននៅវត្តកែវសិក្ខាគីរីស្វារៈ ។ មកដល់ពេលនេះ ពិតមែនតែសភាពការណ៍ស្ងប់ស្ងាត់ល្អ តែកងទ័ពនៅតែត្រៀម លក្ខណៈកសាងពង្រឹងការពារជាតិឲ្យរឹងមាំរហូត ។

នាយឧត្តមសេនីយ៍ **គន់ គីម** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ នាយសេនាធិការចំរុះ និងជាអនុប្រធានទទួលបន្ទុករួម សមរភូមិព្រំដែនកម្ពុជា-ថៃ មានប្រសាសន៍ថា ចំណងសម្ព័ន្ធមេត្រីនេះ ជាការពង្រីកទំនាក់ទំនង លើកកម្ពស់ស្មារតីភាព ឲ្យកាន់តែជិតស្និត ព្រមទាំងលើកទឹកចិត្តកំលាំងស្មារតី ធ្វើឲ្យយើងទាំងអស់គ្នាមានភាពកក់ក្តៅ និងឈានទៅសម្រេចរាល់ភារកិច្ច ក្នុងបុព្វហេតុការពារជាតិ មាតុភូមិជាទីស្នេហារបស់យើង ។

នាយឧត្តមសេនីយ៍ ថ្លែងអំណរគុណ ចំពោះប្រតិភូដែលមានទឹកចិត្ត ជួយដល់កងទ័ពជួរមុខ ក្នុងឱកាសដែលកងទ័ព កំពុងឈរជើង ការពារបូរណភាពទឹកដីតាមតំបន់ព្រំដែន ដែលប្តូរស្លាប់រស់ នៅក្នុងតំបន់ប្រាសាទព្រះវិហារដោយផ្ទាល់ ៕






ស្ថិតក្នុងឱកាសនោះឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ**បានពាំនាំនូវអំណោយបានពីអង្គភាពរដ្ឋាករទឹកស្វយ័តភ្នំពេញរួមមាន ស៊ីម៉ង់៣០តោន សង្កសី៣ពាន់សន្លឹក ការ៉ុងប្រកដី៣ម៉ឺនការ៉ុង ផៃប៉ូវផ្អែម៣០០គក្រ សៀង ២០០គក្រ ទឹកស៊ីអ៊ីវ ១០០យួរ ទឹកត្រី១០០យួរ មីយើង ៣០០កេស កំព្យូទ័រ ០២គ្រឿង ,ព្រីនធ័រ០១គ្រឿង , ឱបករណ៍ GPS ០២គ្រឿង ,ឱបករណ៍វាស់មែត្រ ០១គ្រឿង, ប្រេងម៉ា

ស៊ូត២.០០០លីត្រ ថវិកាសម្រាប់ការពារជួសជុលគ្រឿងចក្រកងទ័ពចំនួន ១០លានរៀល ,ថវិកាចែកជូនដល់ពលទាហ៊ានចំនួន៦០០នាក់សរុប៦លានរៀល និងចំណាយផ្សេងៗចំនួន៣៦លាន៣សែនរៀល។ ដោយឡែកអង្គភាពចំនួន០៨ ដែលបានចូលរួមត្រូវបានឧបត្ថម្ភមួយអង្គភាព១លានរៀល ។ក្រៅពីនោះក៏មានអំណោយបានពីវិស័យឯកជន រួមមាន៖ ក្រុមហ៊ុនស្រាបៀរកម្ពុជាឧបត្ថម្ភស្រាបៀរកម្ពុជាចំនួន១០០កេស និងក្រុមហ៊ុននំស្រួយលីលីឧបត្ថម្ភនំស្រួយ៣០កេស ។ ដោយឡែក ដោយមានសំណើរសុំបន្ថែម ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានឧបត្ថម្ភនូវស៊ីម៉ង់១០តោន ,ដែក៤តោន ,លួសបន្លា១០០គ.ក្រ ដល់កងពលតូចពិសេសឆ័ត្រយោងសម្រាប់ជួសជុលលេណដ្ឋាននិងឧបត្ថម្ភថវិកាចំនួន២.៤៤៥ដុល្លារអាមេរិកដល់ទីបញ្ជាការសន្តិភាព៥មករា សម្រាប់ជួសជុលថែរក្សាសំភារៈម៉ាស៊ីនភ្លើង ហើយឯកឧត្តមបានបញ្ជាក់ថា៖ឯកឧត្តមនឹងខិតខំស្វែងរកប្រភពជំនួយបន្ថែមទៀតតាមលទ្ធភាពជាក់ស្តែង ដើម្បីឧបត្ថម្ភដល់កងទ័ពជួរមុខ ដែលជាដៃគូមិនអាចខ្វះបានរវាងសមរភូមិមុខនិងសមរភូមិក្រោយ ។